01323323

E306/7/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens


ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 08 / 2016
ម៉ោង (Time/Heure) : 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA


អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **យ៉ា សុខន** ជ.ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូរ ឧត្តរា**
ចៅក្រម Claudia FENZ
ចៅក្រម **ធូ មណី**

កាលបរិច្ឆេទ: ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើសារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងស្តីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទិននឹងការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងទទួលបានសារណាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ស្តីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទិននឹងការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈនៅក្រោមបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[1]។ សហមេធាវីនាំមុខ បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់លើផ្នែកនៃអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "ព័ត៌មានបន្ថែមទាក់ទិននឹងអញ្ញត្រកម្មដែលនៅសេសសល់" ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ពាក់ព័ន្ធនឹងវិសាលភាពនៃការចោទប្រកាន់នៃការរំលោភសេពសន្ថវៈនៅក្រោមបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[2]។ ជាពិសេស សហមេធាវីនាំមុខ បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង បញ្ជាក់ថាអង្គជំនុំជម្រះ បានទទួលការចោទប្រកាន់ជាផ្លូវការលើអង្គហេតុនៃការរំលោភផ្លូវភេទ នៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខ ស-២១ និង មន្ទីរសន្តិសុខក្រាំងតាចាន់ នៅក្នុងសំណុំរឿង ០០២/០២ និង ចាត់វិធានការណាមួយអនុលោមតាមវិធានផ្ទៃក្នុង ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន[3]។ នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ មេធាវីការពារក្តី ខៀវ សំផន បានឆ្លើយតបដោយស្នើឱ្យអង្គជំនុំជម្រះបដិសេធលើសំណើសុំនេះ[4]។ សហមេធាវីនាំមុខ បានដាក់ការឆ្លើយតបនៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦[5]។ ការិយាល័យសហព្រះរាជអាជ្ញា ឬ មេធាវីការពារក្តី នួន ជា ពុំបានដាក់សារណានោះទេ។

---

[1] សារណារបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងស្តីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈនៅក្រោមបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឯកសារ E306/7 ("សំណើសុំ")។

[2] សំណើសុំ កថាខណ្ឌ ១។

[3] សំណើសុំ កថាខណ្ឌ ១៦-១៧, ២៨។

[4] *ចម្លើយរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើសុំបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈ* ឯកសារ E306/7/1 កថាខណ្ឌ ២-៣, ៧-១៣ ("ចម្លើយតបរបស់ ខៀវ សំផន")។

[5] ការឆ្លើយតបរបស់សហមេធាវីនាំមុខទៅនឹងចម្លើយរបស់មេធាវីការពារក្តីលោក ខៀវ សំផន តបទៅនឹងសំណើសុំការបញ្ជាក់បំភ្លឺអំពីការរំលោភសេពសន្ថវៈនៅក្រោមបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឯកសារ E306/7/2 ("ការឆ្លើយតប")។ នៅក្នុងអ៊ីម៉ែលចុះថ្ងៃទី ៣១ ខែមីនា និង ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ សហមេធាវីនាំមុខបានស្នើសុំការអនុញ្ញាតដាក់ការឆ្លើយតប

## ២. សារណា

២. សហមេធាវីនាំមុខ បានលើកឡើងថាដីកាដំណោះស្រាយដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលចោទប្រកាន់ចំពោះការប្រព្រឹត្តិដែលចាត់ទុកថាជាការរំលោភផ្លូវភេទ នៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និង មន្ទីរសន្តិសុខស-២១។ សហមេធាវីនាំមុខ បានស្នើថាការប្រព្រឹត្តិ ចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងទម្រង់អមនុស្សធម៌ផ្សេងទៀតដោយសារការរំលោភផ្លូវភេទ អំពើអមនុស្សធម៌ផ្សេងទៀតដោយសារការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និង ការធ្វើទារុណកម្ម ដែលអំពើទាំងនេះត្រូវបានដាក់បញ្ចូលច្បាស់លាស់ក្នុងសេចក្តីសម្រេចស្តីពីការ-បំបែកកិច្ចដំណើរការនីតិវិធីបន្ថែមនៃសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២។ បន្ថែមពីនេះ សហមេធាវីនាំមុខ បានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរបានទទួលការជូនដំណឹងស្តីពីការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈ ចាប់តាំងពីឆ្នាំ ២០០៩ ហើយអង្គហេតុ និង ការចោទប្រកាន់នានាទាក់ទិននឹងបញ្ហានេះ ត្រូវបានដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយរួចមកហើយ លើកលែងតែការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយសារការរំលោភសេព-សន្ថវៈ ថាជាឧក្រិដ្ឋកម្មដាច់ដោយឡែកប៉ុណ្ណោះ[6] ។

៣. សហមេធាវីនាំមុខ បានអះអាងថាសហចៅក្រមស៊ើបអង្កេត មិនបានច្រានចោលការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈនៅក្នុងដីកាដំណោះស្រាយនោះឡើយ ហើយពាក្យពេចន៍ដែលបានប្រើនៅក្នុងដីកាដំណោះស្រាយ អាចនាំឱ្យសន្និដ្ឋានថាការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈ និងភ័ស្តុតាងពាក់ព័ន្ធនៅក្នុងដំណាក់កាលនោះ មិនមែនជា "ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលមេដឹកនាំ ប.ក.ក បានអនុវត្តគោលបំណងរួមនោះឡើយ"។ សហមេធាវីនាំមុខ បានលើកឡើងថា មិនមានដីកាលើកលែងការចោទប្រកាន់ជាក់លាក់ណាមួយ បានធ្វើឡើងទៅតាមលក្ខខណ្ឌតម្រូវនៅក្នុងមាត្រា ១៧៧ នៃ*ក្រមនីតិវិធីព្រហ្មទណ្ឌ*នោះឡើយ[7]។

---

ហើយបានស្នើសុំដាក់ជាភាសាអង់គ្លេសតែមួយភាសា។ សំណើសុំទាំងពីរត្រូវបានអង្គជំនុំជម្រះទទួលយកនៅក្នុងអ៊ីមែលដែលបានបញ្ជូនទៅដោយមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦។

[6] សំណើសុំ កថាខណ្ឌ ២១-២២។ ការឆ្លើយតប កថាខណ្ឌ ២។

[7] សំណើសុំ កថាខណ្ឌ ១៨-២០។ ការឆ្លើយតប កថាខណ្ឌ ២-៤។

01323326



៤. សហមេធាវីនាំមុខ បានអះអាងបន្ថែមថាអង្គជំនុំជម្រះស្ថិតក្រោមកាតព្វកិច្ចវិជ្ជមានក្នុងការធ្វើការពិចារណាលើការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈ ព្រមទាំងធ្វើការសម្រេចអនុលោមតាមវិធាន ៩៨ នៃវិធានផ្ទៃក្នុង ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិរបស់ជនជាប់ចោទ។ សហមេធាវីនាំមុខបានអះអាងថាអង្គជំនុំជម្រះសាលាដំបូងមិនមែនមានត្រឹមតែឆន្ទានុសិទ្ធិក្នុងការកំណត់តាមផ្លូវច្បាប់នូវការចោទប្រកាន់ប៉ុណ្ណោះទេ ប៉ុន្តែមានឆន្ទានុសិទ្ធិក្នុងការជ្រើសរើស និង កំណត់ទម្រង់នៃការទទួលខុសត្រូវលើធាតុផ្សំបទល្មើសដែលពាក់ព័ន្ធ ហើយការកម្រិតលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះក្នុងបញ្ហានេះ គឺថាការកំណត់បទចោទថ្មី មិនត្រូវផ្អែកលើធាតុផ្សំថ្មីឡើយ។ ជាចុងក្រោយ សហមេធាវីនាំមុខ បានលើកឡើងថា ការចោទប្រកាន់នានាត្រូវបានធ្វើឡើងដោយផ្អែកលើភស្តុតាងគ្រប់គ្រាន់ ឬ យ៉ាងណា ហើយថាតើការចោទប្រកាន់ទាំងនេះបង្កើតជាការរំលោភសេពសន្ថវៈ ដែលជាបទល្មើសសារធាតុមួយនោះ ត្រូវកំណត់ដោយអង្គជំនុំជម្រះនៅពេលវាយតម្លៃលើភស្តុតាងទាំងឡាយនៅដំណាក់កាលធ្វើសាលក្រម។ រហូតដល់ដំណាក់កាលនោះ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការស្តាប់ភស្តុតាងទាក់ទិននឹងការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ និងមានកាតព្វកិច្ចធ្វើការសម្រេចលើអង្គហេតុ និង អង្គច្បាប់ដែលជាប់ពាក់ព័ន្ធ[8]។

៥. មេធាវីការពារក្តី ខៀវ សំផន បានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូង បានសម្រេចពីរលើករួចមកហើយថាជនជាប់ចោទ មិនត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះឡើយ ហើយចំពោះសំណើសុំនេះ ជាក់ស្តែងស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញលើសេចក្តីសម្រេចដែលអង្គជំនុំជម្រះបានធ្វើរួចហើយ[9]។ មេធាវីការពារក្តី ខៀវ សំផន បានសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង អាចទទួលពិចារណាលើតែការចោទប្រកាន់លើអង្គហេតុនានាដែលជនជាប់ចោទត្រូវបានចោទប្រកាន់ ដោយមិនរួមបញ្ចូលការចោទប្រកាន់ផ្សេងទៀតៗ ដែលគ្រាន់តែមានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយនោះឡើយ។ មេធាវីការពារក្តី បានលើកឡើងថាសហចៅក្រមស៊ើបអង្កេត បានសន្និដ្ឋាននៅក្នុងដីកាដំណោះស្រាយរួចមកហើយថាជនជាប់ចោទទាំងពីរ មិនត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើអង្គហេតុផ្សេងៗដែល

---

[8] សំណើសុំ កថាខណ្ឌ ២៣-២៦។ ការឆ្លើយតប កថាខណ្ឌ ២។

[9] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២-៣។

01323327



គ្រាន់តែមានការបញ្ជាក់នៅក្នុងដីការដំណោះស្រាយនោះឡើយ។ មេធាវីការពារក្តី ខៀវ សំផន បាន លើកឡើងបន្ថែមទៀតថា ទោះបីជាមិនមានដីកាលើកលែងការចោទប្រកាន់ណាមួយជាក់លាក់ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតបានសម្រេចយ៉ាងច្បាស់លាស់ លើបញ្ហានេះដោយការលើកលែងការចោទប្រកាន់ដោយប្រយោលនៅក្នុងដីការដំណោះស្រាយ[10]។

៦. មេធាវីការពារក្តី ខៀវ សំផន អះអាងថា អង្គជំនុំជម្រះសាលាដំបូង មិនមានសមត្ថកិច្ចក្នុងការកែប្រែការកំណត់បទចោទ ដែលពុំទទួលបានតាមដីកាដំណោះស្រាយដែលត្រូវបានកែប្រែឡើយ។ មេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់ថា ផ្ទុយពីទឡ្ហីករណ៍របស់សហមេធាវីនាំមុខ អង្គជំនុំជម្រះបានកំណត់យ៉ាងច្បាស់អំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចបានបង្ហាញច្បាស់លាស់នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ និង នៅក្នុងសេចក្តីសម្រេចមុន និង ជាបន្តបន្ទាប់ដែលកំណត់វិសាលភាពនៃរឿងក្តីនេះ[11]។

## ៣. ច្បាប់ជាធរមាន

៧. វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

> សាលក្រម ត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ អង្គជំនុំជម្រះ អាចផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ។

៨. វិធាន ៩៨(៣) នៃវិធានផ្ទៃក្នុង ចែងថា៖ “អង្គជំនុំជម្រះត្រូវពិនិត្យថាតើអំពើនោះជាបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង ថាតើជនជាប់ចោទបានប្រព្រឹត្តអំពើនោះដែរ ឬ ទេ”។

---

[10] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៧-១៣។

[11] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១៥-១៨។

## ៤. សំអាងហេតុ

៩. អង្គជំនុំជម្រះ ពិចារណាឃើញថាវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទិននឹងការចោទប្រកាន់ស្តីពីការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានបង្ហាញជាក់ច្បាស់ដោយដីកាដំណោះស្រាយ ដូចដែលបានកែប្រែដោយអង្គបុរេជំនុំជម្រះ ដីកាបង្គាប់ឱ្យបំបែកកិច្ចដំណើការនីតិវិធីបន្ថែម សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ព័ត៌មានបន្ថែមទាក់ទងអញ្ញត្រកម្មដែលនៅសេសសល់" និង "សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំតទល់ក្នុងចំណោមសាក្សី ស្រី ថន, ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន និង សូត្រ សាំង និង ការដាក់បង្ហាញកំណត់ហេតុជាខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយរបស់ សយ សែន"។ អង្គជំនុំជម្រះនឹងពិនិត្យសេចក្តីសម្រេចនីមួយៗក្នុងកថាខណ្ឌខាងក្រោម ដើម្បីផ្តល់ការបញ្ជាក់បំភ្លឺ ដែលបានស្នើសុំដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

១០. យោងតាមការរៀបរាប់ខាងលើ វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលា-ដំបូងកែប្រែការកំណត់បទចោទ និង ទម្រង់នៃការទទួលខុសត្រូវ ប៉ុន្តែការកំណត់បទចោទឡើងវិញត្រូវកម្រិតត្រឹមអង្គហេតុនានាដែលមានក្នុងដីកាដំណោះស្រាយដែលត្រូវបានកែប្រែប៉ុណ្ណោះ។ ការដាក់កំហិតយ៉ាងជាក់លាក់លើការកំណត់ឡើងវិញនេះ ត្រូវបានបញ្ជាក់ម្តងទៀតនៅក្នុងលក្ខខណ្ឌនៃវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ដែលបានកំណត់ថា ធាតុផ្សំថ្មីនៃបទចោទមិនអាចបញ្ចូលបាននោះឡើយ[12]។ អង្គជំនុំជម្រះ ត្រូវធានាថាសមត្ថកិច្ចនៃការកំណត់បទចោទជាថ្មី គឺត្រូវបានអនុវត្តអនុលោមតាមការធានាឱ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌មួយចំនួនដូចជា៖ (i) គ្មានការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ (ii) បទល្មើសដែលចោទជាបញ្ហាត្រូវស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក និង (iii) ទម្រង់នៃការទទួលខុសត្រូវដែលចោទគឺជាទម្រង់ដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក[13]។

១១. សំណើនេះផ្អែកលើអង្គហេតុនានានៅក្នុងដីកាដំណោះស្រាយ ដែលបានរៀបរាប់ពីការរំលោភ-សេពសន្ថវៈ ដែលបានកើតឡើងនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ សហមេធាវីនាំមុខ

---

[12] សាលក្រមជំនុំជម្រះ *កាំង ហ្គេកអ៊ាវ* ឯកសារ E188, កថាខណ្ឌ ៤៩៣-៤៩៤។

[13] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ ៤៩២-៤៩៦។

បានស្នើសុំឱ្យមានការកំណត់អង្គហេតុទាំងនោះឡើងវិញ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់នៃការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងទៀតដោយសារការរំលោភសេពសន្ថវៈ ឬ អំពើអមនុស្សធម៌ផ្សេងទៀត ដោយសារការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ ការធ្វើទារុណកម្ម និង អំពើអមនុស្សធម៌ដទៃទៀត ត្រូវបានកំណត់ជាបទល្មើសដាច់ដោយឡែកទាំងនៅក្នុងច្បាប់ អ.វ.ត.ក និង នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ ហេតុដូច្នេះ មុនធ្វើការសម្រេចកំណត់អង្គហេតុទាំងនោះឡើងវិញ អង្គជំនុំជម្រះ ត្រូវធ្វើការពិចារណាលើអង្គហេតុជាក់លាក់នានាដែលជាមូលដ្ឋានដែលជនជាប់ចោទ ត្រូវបានចោទប្រកាន់ជាផ្លូវការ[14]។

១២. អង្គជំនុំជម្រះរម្លឹកថាផ្នែកសម្រេចសេចក្តីនៃដីកាដំណោះស្រាយ មានអំនះអំនាងគ្រប់គ្រាន់ដែលថាជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់នៃការរំលោភសេពសន្ថវៈក្នុងចំណោមឧក្រិដ្ឋកម្មដទៃទៀត[15]។ ទោះបីជាមិនមានសញ្ញាណណាមួយបញ្ជាក់ថា តើឧក្រិដ្ឋកម្មនៃការរំលោភសេពសន្ថវៈ ដែលត្រូវបានចោទប្រកាន់រួមមានការរំលោភសេពសន្ថវៈទាំងក្នុង និងក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះបានសម្រេចថាផ្នែកនៃដីកាដំណោះស្រាយនឹងត្រូវធ្វើការពិចារណាជាមួយកថាខណ្ឌពាក់ព័ន្ធនៅក្នុងដីកាដំណោះស្រាយដែលបានសម្រេចលើការកំណត់អង្គច្បាប់នៃការរំលោភសេពសន្ថវៈ។

១៣. អង្គជំនុំជម្រះ រម្លឹកថាក្នុងផ្នែកទាក់ទិនការរំលោភសេពសន្ថវៈនៅក្នុងដីកាដំណោះស្រាយបញ្ជាក់ថា "មានការបង្ហាញច្បាស់លាស់ថាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការរំលោភផ្លូវភេទ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងកាលៈទេសៈផ្សេងៗជាច្រើន ជាអាទិ៍នៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ ភូមិភាគឧត្តរ ព្រៃដំរីស្រុក មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខសង់ ព្រមទាំងនៅក្នុងសហករណ៍ត្រាំកក់"[16]។ ដីកាដំណោះស្រាយ បានសម្រេចទៀតថា "ចំពោះទីតាំងនីមួយៗដូចបានរៀបរាប់ខាងលើ ចារីបានប្រព្រឹត្តដោយចេតនានូវការលុកលុយផ្លូវភេទទៅលើជនរងគ្រោះ តាមវិធីបង្ខំ គ្មានការព្រមព្រៀងគ្នាពីជនរងគ្រោះ ដែលចារីបានដឹង

[14] សាលក្រមសំណុំរឿង ០០២/០១, ឯកសារ E313, កថាខណ្ឌ ១៧៦-១៧៧, ៤៣៥-៤៣៧។ សូមមើលផងដែរ សាលក្រមជំនុំជម្រះ *កាំង ហ្គេកអ៊ាវ*, ឯកសារ E188, កថាខណ្ឌ ៣៦៧-៣៧១។

[15] ដីកាដំណោះស្រាយ, សំណុំរឿង ០០២, ឯកសារ D427, ទំព័រ ៣៩៧-៣៩៨។

[16] ដីកាដំណោះស្រាយ, សំណុំរឿង ០០២, ឯកសារ D427, កថាខណ្ឌ ១៤២៦។

01323330



ច្បាស់ ហើយធាតុផ្សំជាបរិបទនៃការរំលោភផ្លូវភេទដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានបំពេញ”[17]។

១៤. ទោះបីជាមានសំអាងហេតុច្បាស់លាស់ពីការរំលោភផ្លូវភេទនៅក្រៅការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏ដីកាដំណោះស្រាយបានសន្និដ្ឋានថាការរំលោភផ្លូវភេទនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានចាត់ទុកថា “ស្ថិតក្នុងចំណោមឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រើប្រាស់ដោយមេដឹកនាំ ប.ក.ក ដើម្បីអនុវត្តគោលបំណងរួមឡើយ”[18]។ អាស្រ័យហេតុនេះ ធាតុផ្សំនីត្យានុកូលនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ការរំលោភផ្លូវភេទនៅក្នុងដីកាដំណោះស្រាយ ត្រូវបានកំណត់ត្រឹមតែអំពើរំលោភផ្លូវភេទក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំប៉ុណ្ណោះ[19]។

១៥. ផ្អែកលើសំអាងហេតុទាំងនេះ បទល្មើសរំលោភសេពសន្ថវៈ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ ក្នុងផ្នែកនៃដីកាដំណោះស្រាយ មិនត្រូវបានរួមបញ្ចូលការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងមន្ទីរសន្តិសុខ និងសហករណ៍នោះឡើយ។ គ្មានបទល្មើសណាផ្សេងទៀត បានផ្អែកលើអង្គហេតុនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ។ ការបកស្រាយនេះ ត្រូវបានបញ្ជាក់បន្ថែមដោយទម្រង់នានានៃការទទួលខុសត្រូវដែលមានក្នុងដីកាដំណោះស្រាយ ដែលគ្រាន់តែពិចារណាលើការរំលោភសេពសន្ថវៈក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំប៉ុណ្ណោះ[20]។

១៦. នៅក្នុងបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះ បានរកឃើញថាអង្គហេតុដែលត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់នៃការរំលោភផ្លូវ

---

[17] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ ១៤២៧។

[18] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ ១៤២៩។

[19] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ ១៤៣០។

[20] សូមមើលផ្នែកទាក់ទងសំអាងហេតុស្តីពីទម្រង់នៃការទទួលខុសត្រូវ, ឯកសារ D427, កថាខណ្ឌ ១៥២១ *និង ផ្នែកខាងក្រោម*
។

ភេទ ដែលជា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់នៃអំពើអមនុស្សធម៌ផ្សេងទៀត"[21]។ ទោះជាយ៉ាងណាក្តី ការសម្រេចនេះ ត្រូវបានកម្រិតយ៉ាងច្បាស់លាស់ត្រឹមការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ។

១៧. នៅដំណាក់កាលជំនុំជម្រះ ផ្ទុយពីការសន្និដ្ឋានរបស់សហមេធាវីនាំមុខ ដីកាបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម មិនមានដាក់បញ្ចូលការចោទប្រកាន់លើការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលមិនត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយនោះឡើយ[22]។ ភាពស៊ីសង្វាក់នៃជំហររបស់អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះពីររួចមកហើយ។ លើកទីមួយ នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "មិនមានមូលដ្ឋានគតិយុត្តិសម្រាប់សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមការចោទប្រកាន់ទៅក្នុងដីកាដំណោះស្រាយចំពោះការរំលោភសេពសន្ថវៈ (នៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ) ដែលបានកើតឡើងនៅមន្ទីរសន្តិសុខបានឡើយ..."[23]។ អង្គជំនុំជម្រះ រម្លឹកថា "សហចៅក្រមស៊ើបអង្កេតបានសម្រេចយ៉ាងជាក់លាក់ថាទោះបីជាការរំលោភសេពសន្ថវៈបានកើតឡើងតាមមន្ទីរសន្តិសុខក៏ដោយ ក៏ជនជាប់ចោទមិនត្រូវជាប់ទំនួលខុសត្រូវចំពោះបទល្មើសទាំងនោះឡើយ ដោយសារតែភស្តុតាងទាំងនោះ មិនបានគាំទ្រលើសម្មតិកម្ម ដែលថាមេដឹកនាំ ប.ក.ក បានប្រើប្រាស់ការរំលោភសេពសន្ថវៈជាគោលនយោបាយនៅតាមមន្ទីរសន្តិសុខ" ហើយ "ទោះបីជាអង្គជំនុំជម្រះ អាចផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់ក្នុងដីកាដំណោះស្រាយនោះ លុះត្រាតែធាតុផ្សំថ្មីនៃបទល្មើស ត្រូវបានរកឃើញ (វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង) អង្គជំនុំជម្រះ មិនមានសមត្ថកិច្ចក្នុងការបញ្ចូល

[21] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារ D427/1/26, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ៧(២)។ សូមមើលផងដែរ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារ D427/4/14, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ ២(១២) និង សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ជំទាស់ដីកាដំណោះស្រាយ, ឯកសារ D427/4/14, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ២(១២)។

[22] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង០០២/០២, ឯកសារ E301/9/1, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤។ សូមមើលផងដែរ បញ្ជីកថាខណ្ឌ និង ផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធសំណុំរឿង០០២/០២, ឯកសារ E301/9/1.1, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤, ទំព័រ ៤។

[23] ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់, ឯកសារ E306, កថាខណ្ឌ ៣។

អង្គហេតុ ឬ ការចោទប្រកាន់ថ្មី ដែលត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះទៅក្នុងដីកាដំណោះស្រាយនោះឡើយ”[24]។

១៨. នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ម្តងទៀតថាការចោទប្រកាន់នៃការរំលោភសេពសន្ថវៈក្រៅការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនមានរួមបញ្ចូលនៅក្នុងដីកាដំណោះស្រាយឡើយ។ យោងលើសេចក្តីសម្រេចក្នុងឯកសារ E306 អង្គជំនុំជម្រះ បានរម្លឹកថាអង្គជំនុំជម្រះ បានបដិសេធលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំចោទប្រកាន់បន្ថែម លើការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបានកើតឡើងនៅមន្ទីរសន្តិសុខ និង សហករណ៍នានាដូចដែលបានលើកឡើងក្នុងដីកាដំណោះស្រាយ ហើយអង្គជំនុំជម្រះ បានកត់សម្គាល់ថាក្នុងករណីមន្ទីរសន្តិសុខក្រាំងតាចាន់ ជនជាប់ចោទ មិនត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះការប្រព្រឹត្តិនានាផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវផ្សេងទៀតនោះឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះ បានកត់សម្គាល់ថាការរំលោភផ្លូវភេទ ដែលបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ អាចពាក់ព័ន្ធនឹងប្រធានបទផ្សេងទៀត ដូចជាលក្ខខ័ណ្ឌនានាក្នុងមន្ទីរសន្តិសុខនោះ[25]។

១៩. អង្គជំនុំជម្រះ យល់ឃើញថាក្នុងករណីដែលសំណើនេះត្រូវបានឯកភាព សំណើនេះនឹងបន្ថែមការចោទប្រកាន់ថ្មី ឬ បង្កើតទម្រង់នៃការទទួលខុសត្រូវថ្មីប្រឆាំងជនជាប់ចោទ សម្រាប់ការចោទប្រកាន់ ដែលមិនត្រូវបានចោទជាផ្លូវការក្នុងដីកាដំណោះស្រាយ។ បើដូច្នេះមែន មានន័យថាអង្គជំនុំជម្រះអនុវត្តហួសសមត្ថកិច្ចរបស់ខ្លួនដែលមាន អនុលោមតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។

២០. ជាចុងក្រោយ ផ្ទុយពីសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន អង្គជំនុំជម្រះ មិនត្រូវបានស្នើសុំឲ្យធ្វើការពិចារណាឡើងវិញលើការសម្រេចមុនៗរបស់ខ្លួនស្តីពីបញ្ហានេះនោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះគ្រាន់តែផ្តល់ការបញ្ជាក់លើវិសាលភាពនៃការចោទប្រកាន់ប្រឆាំង

---

[24] ដូចឯកសារយោងខាងលើ ។

[25] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឲ្យមានការតទល់គ្នារវាង សាក្សី ស្រី ថន ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន និង ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង និង ស្នើសុំឯកសារថតសំឡេងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សយ សែន, ឯកសារ E348/4, កថាខណ្ឌ ១១។

ជនជាប់ចោទ ជុំវិញការរំលោភសេពសន្ថវៈក្នុងសំណុំរឿង ០០២/០២ ដូចដែលបានបង្ហាញនៅក្នុងសេចក្តីសម្រេចពាក់ព័ន្ធនានា ដែលត្រូវបានពិចារណាខាងលើ។

**តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច÷**

**បដិសេធ** សំណើសុំឱ្យកំណត់ឡើងវិញ នូវបទចោទនៃការរំលោភសេពសន្ថវៈនៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និង មន្ទីរសន្តិសុខ ស-២១។

ភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦

ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER * CHAMBRE DE PREMIÈRE INSTANCE * E.C.C.C * C.E.T.C

យ៉ា សុខន